J Trust Royal Bank

Tel: +855 23 999 000
Email: ccc@jtrustroyal.com
SWIFT: TCABKHPP
URL: www.jtrustroyal.com

# បទបញ្ញត្តិ និងលក្ខខណ្ឌ នៃប្រាក់កម្ចីផ្ទាល់ខ្លួនរបស់ ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់

មានសុពលភាពចាប់ពី ខែសីហា ឆ្នាំ២០១៩

J Trust Royal Bank

តារាងមាតិកា ទំព័រ


| | | |
|---|---|---|
| | ការទទួលស្គាល់ទូទៅ | 1 |
| | និយមន័យ | 2 |
| 1. | កម្ចី និងការបើកប្រាក់ | 2 |
| 2. | កម្រៃសេវា និងការប្រាក់ | 2 |
| 3. | ការទូទាត់សង | 3 |
| 4. | ព្រឹត្តិការណ៍នៃការរំលោភកាតព្វកិច្ច | 3 |
| 5. | សិទ្ធិរបស់ធនាគារក្នុងព្រឹត្តិការណ៍មានករណីរំលោភកាតព្វកិច្ច | 4 |
| 6. | ការទូទាត់សងជាមុន និងការលុបចោល | 4 |
| 7. | ការអនុញ្ញាត និងការកាត់យកឥណទាន និងសំណងការខូចខាត | 5 |
| 8. | ការប្រើប្រាស់កម្ចី | 5 |
| 9. | មរណៈភាពរបស់អ្នកខ្ចី | 6 |
| 10. | ការបង្ហាញព័ត៌មាន | 6 |
| 11. | ការជូនដំណឹង និងទំនាក់ទំនងតាមរយៈធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ | 7 |
| 12. | ការទទួលការណែនាំ និងទំនាក់ទំនងដោយអ្នកខ្ចី | 8 |
| 13. | ការប្រឆាំងនឹងការសំអាតប្រាក់ និងបញ្ញត្តិច្បាប់នានា | 8 |
| 14. | ច្បាប់គ្រប់គ្រង ការដោះស្រាយវិវាទ និងការកែប្រែលើបញ្ញត្តិ និងលក្ខខណ្ឌ | 9 |
| 15. | បញ្ញត្តិទូទៅ | 10 |


ឯកសារនេះត្រូវអានជាមួយកូនសៀវភៅនិយាយពីថ្លៃសេវាកម្ម និងកម្រៃផ្សេងៗ នៃប្រាក់កម្ចីផ្ទាល់ខ្លួនរបស់ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ ។ ឯកសារទាំងពីរនេះ បង្កើតបានជាលក្ខខណ្ឌដែលត្រូវយកមកអនុវត្តជាមួយផលិតផលនេះ ។

# បទបញ្ញត្តិ និងលក្ខខណ្ឌនៃប្រាក់កម្ចីផ្ទាល់ខ្លួនរបស់ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់

## ការទទួលស្គាល់ទូទៅ

បញ្ញត្តិ និងលក្ខខណ្ឌនៃប្រាក់កម្ចីផ្ទាល់ខ្លួនរបស់ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ (ជា "បញ្ញត្តិ និងលក្ខខណ្ឌ") ទាំងនេះរួមបញ្ចូលជាមួយនឹងទម្រង់ពាក្យស្នើសុំ (ជា "ពាក្យស្នើសុំ") បង្កើតបានជាកិច្ចព្រមព្រៀងកម្ចីរវាងធនាគារ និងអ្នកខ្ចី។ ដើម្បីជាសក្ខីភាព អ្នកខ្ចីយល់ព្រមអនុវត្តតាមបញ្ញត្តិ និងលក្ខខណ្ឌនៃកិច្ចព្រមព្រៀងនេះ ដោយចុះហត្ថលេខាលើ ពាក្យស្នើសុំចុះកិច្ចព្រមព្រៀងកម្ចីនោះ។

បញ្ញត្តិ និងលក្ខខណ្ឌនេះត្រូវអនុវត្តរួមគ្នាជាមួយបញ្ញត្តិ និងលក្ខខណ្ឌទូទៅនៃប្រាក់កម្ចីផ្ទាល់ខ្លួនរបស់ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ និងបញ្ញត្តិ និងលក្ខខណ្ឌផ្សេងទៀតលើផលិតផល និងសេវាកម្មដែលអាចអនុវត្តបានទៅលើផលិតផល និងសេវាកម្មដែលបានផ្តល់ជូនអ្នកខ្ចី។ បញ្ញត្តិ និងលក្ខខណ្ឌទាំងនេះ អាចរកបានតាមការស្នើសុំនៅតាមសាខារបស់ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ លើកលែងតែមានការបញ្ជាក់ច្បាស់លាស់ បញ្ញត្តិ និងលក្ខខណ្ឌនេះត្រូវមានឧត្តមានុភាព ប្រសិនបើមានភាពមិនស្របគ្នារវាងបញ្ញត្តិ និងលក្ខខណ្ឌនេះ ទៅនឹងបញ្ញត្តិ និងលក្ខខណ្ឌដទៃទៀត។

ការទទួលយកទម្រង់ពាក្យស្នើសុំ ធនាគារគ្មានកាតព្វកិច្ចត្រូវតែយល់ព្រមផ្តល់កម្ចីណាមួយឱ្យអ្នកខ្ចីនោះទេ ទោះស្ថិតនៅក្នុងមធ្យោបាយណាមួយក៏ដោយ ប៉ុន្តែពាក្យស្នើសុំនេះនឹងចងភ្ជាប់កាតព្វកិច្ចរបស់អ្នកខ្ចីទៅនឹងបញ្ញត្តិ និងលក្ខខណ្ឌទាំងនេះ។

ការផ្តល់កម្ចីត្រូវឈរលើមូលដ្ឋានមិនត្រូវតែផ្តល់ និងត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យរបស់ធនាគារជាប្រចាំ។ ធនាគាររក្សាសិទ្ធិគ្រប់យ៉ាងក្នុងការៈ (1) ការកាត់បន្ថយ ឬការលុបចោលកម្ចីនេះ (ឬបំណែកណាមួយនោះ) គ្រប់ពេល និង/ឬ (2) ទាមទារឱ្យទូទាត់សងប្រាក់ទាំងអស់ ប្រសិនបើមានព្រឹត្តិការណ៍នៃការរំលោភលើកិច្ចព្រមព្រៀង (ដូចមានបញ្ជាក់នៅក្នុងប្រការ 4 ខាងក្រោម) កើតមានឡើង ឬអ្នកខ្ចីបានបំពានកាតព្វកិច្ចណាមួយរបស់ខ្លួនដូចមានចែងនៅក្នុងបញ្ញត្តិ និងលក្ខខណ្ឌដែលអ្នកខ្ចីត្រូវអនុវត្ត។

អ្នកខ្ចីត្រូវធានាអះអាងចំពោះធនាគារអំពីព័ត៌មានពិតប្រាកដ និងច្បាស់លាស់ដែលតម្រូវឱ្យផ្តល់ជូនធនាគារគ្រប់ពេលដែលមានកម្ចី ហើយអ្នកខ្ចីត្រូវបង្ហាញរាល់ព័ត៌មានទាំងឡាយដែលទាក់ទងទៅនឹងទ្រព្យសកម្ម ឬស្ថានភាពហិរញ្ញវត្ថុរបស់ខ្លួន ក៏ដូចជាព័ត៌មានដែលអាចប៉ះពាល់ជាអវិជ្ជមានចំពោះលទ្ធភាពក្នុងការបំពេញកាតព្វកិច្ចរបស់អ្នកខ្ចីដូចមានចែងនៅក្នុងបញ្ញត្តិ និងលក្ខខណ្ឌនេះ។

## និយមន័យ

និយមន័យដែលមានចែងដូចខាងក្រោមនេះមានអានុភាពអនុវត្តចំពោះបញ្ញត្តិ និងលក្ខខណ្ឌនេះទាំងស្រុង លើកលែងតែមានបញ្ជាក់ផ្សេងពីនេះ៖

"ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់" ឬ "ធនាគារ" មានន័យថា ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ ឬសិទ្ធិវ័ន្ត ឬសន្តតិជនណាមួយរបស់ធនាគារនេះ។

"កម្ចី" មានន័យថា កម្ចីជាលក្ខណៈផ្ទាល់ខ្លួនដែលធនាគារផ្តល់ឱ្យអ្នកខ្ចី។

"អ្នកខ្ចី" មានន័យថា បុគ្គលដែលបានចុះហត្ថលេខាលើទម្រង់ពាក្យស្នើសុំខ្ចី។

## 1. កម្ចី និងការបើកប្រាក់

1.1 អ្នកខ្ចីអាចដកយកកម្ចីតែម្តងប៉ុណ្ណោះ នៅក្នុងពេលដែលធនាគារបានយល់ព្រមផ្តល់ឱ្យ។

1.2 សេចក្តីសម្រេចរបស់ធនាគារជាសេចក្តីសម្រេចចុងក្រោយ និងចងកាតព្វកិច្ចចំពោះអ្នកខ្ចី ចំពោះពេលវេលា និងចំនួនកម្ចីដោយមិនគិតពីសំណើដែលមាននៅក្នុងពាក្យស្នើសុំរបស់អ្នកខ្ចីឡើយ។

1.3 អាស្រ័យទៅលើប្រភេទអតិថិជន អ្នកខ្ចីត្រូវតែបើក និងត្រូវរក្សាគណនីប្រាក់បៀវវត្សរ៍ ឬគណនីប្រតិបត្តិជាប្រាក់ដុល្លារអាមេរិច (ជា "គណនី") នៅធនាគារសម្រាប់កម្ចីនេះ។ កម្ចីនេះ ត្រូវបានផ្តល់ឱ្យជាប្រាក់ដុល្លារអាមេរិកទៅក្នុងគណនី។

## 2. កម្រៃសេវា និងការប្រាក់

2.1 អត្រាការប្រាក់ត្រូវគណនា 1ឆ្នាំម្តងជារៀងរាល់ឆ្នាំ ដែលមានរយៈពេល 365 ថ្ងៃក្នុង 1 ឆ្នាំ។

2.2 អត្រាការប្រាក់នេះត្រូវបូកបន្ថែមជារៀងរាល់ថ្ងៃ ដោយធ្វើការទូទាត់ទៅតាមការថយចុះនៃសមតុល្យ។

2.3 គ្រប់ពេលធនាគារអាចកែប្រែវិធីគណនាក្នុងការទូទាត់ ភាពញឹកញាប់ និងរាល់បញ្ញត្តិនៃការទូទាត់សងដែលមានជាអាទិ៍ អត្រាការប្រាក់ កម្រៃសេវា និងសោហ៊ុយផ្សេងៗ។

2.4 អ្នកខ្ចីទទួលស្គាល់ និងយល់ព្រមថា ប្រសិនបើវិធីគណនាអត្រាការប្រាក់ដែល

ធនាគារបានអនុវត្តធ្វើឱ្យមានសំណល់សមតុល្យហួសកាលកំណត់ត្រូវសងនៅដំណាក់កាលចុងក្រោយ វានឹងក្លាយជាផ្នែកមួយនៃប្រាក់សងដំណាក់កាលចុងក្រោយដែលត្រូវសងជាមួយប្រាក់សងដំណាក់កាលចុងក្រោយ ។

## 3. ការទូទាត់សង

3.1 អ្នកខ្ចីត្រូវទូទាត់សងឱ្យធនាគារតាមការទាមទារតាំងពីលើកដំបូងនូវចំនួនដែលដល់កាលកំណត់ត្រូវសង បូករួមនិងរាល់កំណើនការប្រាក់ និងរាល់កម្រៃសេវាដែលអាចអនុវត្តចំពោះកម្ចីនោះ ។ ការទូទាត់សងត្រូវធ្វើឡើងជាប្រាក់ដុល្លារអាមេរិក ។

3.2 ប្រាក់ដើម និងការប្រាក់នៃកម្ចីនេះត្រូវទូទាត់សងជាដំណាក់កាលដែលមានទឹកប្រាក់ចំនួនស្មើៗគ្នាជារៀងរាល់ខែ (ជា "ប្រាក់សំណងប្រចាំខែ") ដែលត្រូវចាប់ផ្តើមអនុវត្តពី 1 ខែបន្ទាប់ពីថ្ងៃដែលបានបើកយកប្រាក់តាមមធ្យោបាយកាត់កងយកឥណទានពីគណនីរបស់អ្នកខ្ចីរហូតដល់កម្ចីនោះត្រូវបានទូទាត់សងគ្រប់ចំនួន ។

3.3 ធនាគារអាចអនុញ្ញាតឱ្យអ្នកខ្ចីធ្វើការទូទាត់សងប្រាក់នូវចំនួនផ្សេងៗ ក្រៅពីចំនួននៃប្រាក់សំណងប្រចាំខែនោះម្តងម្កាល ។

## 4. ព្រឹត្តិការណ៍នៃការរំលោភកាតព្វកិច្ច

រាល់ព្រឹត្តិការណ៍ដែលរាយនៅខាងក្រោម ត្រូវចាត់ទុកជាព្រឹត្តិការណ៍នៃការរំលោភកាតព្វកិច្ច៖

(ក) មិនធ្វើការទូទាត់សង៖ អ្នកខ្ចីខកខានមិនបានទូទាត់សងប្រាក់ឱ្យបានគ្រប់ចំនួនដែលដល់កាលកំណត់ត្រូវសង ឬដែលត្រូវសងទៅធនាគារនៅថ្ងៃដែលត្រូវសង ។

(ខ) បំពានកាតព្វកិច្ច៖ អ្នកខ្ចីបានបំពានលើកាតព្វកិច្ចណាមួយរបស់ខ្លួន ដូចមានចែងនៅក្នុងកិច្ចព្រមព្រៀងកម្ចីនេះ ។

(គ) ផ្តល់ព័ត៌មានខុស៖ រាល់អំណះអំណាង ឬព័ត៌មានដែលអ្នកខ្ចីបានផ្តល់ឱ្យធនាគារ (ដោយផ្ទាល់មាត់ ឬដោយលាយលក្ខណ៍អក្សរ) ខុសពីការពិត ឬមិនត្រឹមត្រូវ ឬអាចនាំឱ្យយល់ច្រឡំទៅលើទិដ្ឋភាពណាមួយ ។

(ឃ) ផ្ទុយនឹងច្បាប់៖ កម្ចីនេះត្រូវបានយកទៅប្រើប្រាស់ខុសគោលដៅ ឬមិនស្របច្បាប់  ឬបញ្ញត្តិ បន្ទាប់បន្សំក្នុងការផ្តល់កម្ចីដែលបណ្តាលឱ្យធនាគារបំពានលើច្បាប់ណាមួយរបស់ព្រះរាជាណាចក្រកម្ពុជា ។

(ង) អ្នកខ្ចីបានទទួលមរណៈភាពបណ្តាល ឱ្យក្ស័យធន ឬទទួលស្គាល់ពីអសមត្ថភាពក្នុងការទូទាត់សងរាល់បំណុលដែលមានជាមួយម្ចាស់បំណុលរបស់ខ្លួន ។

(ច) រាល់ដីការបញ្ជា អស្សាមិករណ៍ ការរឹបអូស ឬការអនុវត្តសិទ្ធិអំណាចណាមួយដែលប៉ះពាល់ដល់ទ្រព្យសកម្មរបស់អ្នកខ្ចី ។

## 5. សិទ្ធិរបស់ធនាគារក្នុងព្រឹត្តិការណ៍មានករណីរំលោភកាតព្វកិច្ច

នៅពេលមានព្រឹត្តិការណ៍រំលោភកាតព្វកិច្ចណាមួយកើតឡើង ធនាគារមានសិទ្ធិអនុវត្តនូវវិធានការដូចតទៅ៖

(ក) ប្រកាសឱ្យទូទាត់សងនូវចំនួនទឹកប្រាក់ដល់កំណត់សង និងទាមទារឱ្យទូទាត់សងនូវចំនួនទឹកប្រាក់ដែលនៅសល់ បូករួមនិងកំណើនការប្រាក់ និងកម្រៃសេវានិងប្រាក់ទាំងនោះត្រូវក្លាយជាប្រាក់ ដល់កាលកំណត់ទូទាត់សងភ្លាមៗ ។

(ខ) ដោយគ្មានជូនដំណឹងជាមុនដល់អ្នកខ្ចី ធនាគារអនុវត្តវិធានការ ឬធ្វើសកម្មភាពណា មួយដើម្បីទទួលបានប្រាក់សំណងណាមួយដែលអ្នកខ្ចីជំពាក់ធនាគារ មានជាអាទិ៍ ការរឹបអូស និង/ឬការកាត់កងទ្រព្យសកម្មណាមួយរបស់អ្នកខ្ចីដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ធនាគារ ការចាត់តាំងភ្នាក់ងារណាមួយឱ្យដោះស្រាយនិងប្រមូលបំណុលពីអ្នកខ្ចី ដំណើរនីតិវិធីតាមច្បាប់ ឬដាក់បណ្តឹងនានាដែលធនាគារយល់ថាសមស្រប ។

(គ) បង្កកប្រតិបត្តិការលើគណនី និង/ឬគណនីផ្សេងទៀតរបស់អ្នកខ្ចីជាមួយធនាគារ និងកាត់យកឥណទានដែលមាននៅក្នុងគណនីនោះ ដើម្បីទូទាត់សងបង្គ្រប់នូវចំនួនដែលអ្នកខ្ចីនៅជំពាក់ធនាគារដោយមិនជូនដំណឹងជាមុនឡើយ ។ ប្រសិនបើរូបិយប័ណ្ណក្នុងគណនីនោះមិនមែនជាប្រាក់ដុល្លារអាមេរិក ធនាគារមានសិទ្ធិប្តូររូបិយប័ណ្ណនោះទៅជា រូបិយប័ណ្ណដុល្លារអាមេរិកតាមអត្រាការប្រាក់ដែលកំពុងអនុវត្តបច្ចុប្បន្នរបស់ធនាគារ ។

## 6. ការទូទាត់សងជាមុន និងការលុបចោល

6.1 អ្នកខ្ចីអាចស្នើសុំឱ្យទូទាត់សងកម្ចីជាមុន ឬលុបចោលនូវកម្ចីនោះ (ឬប្រាក់ដែលនៅសេសសល់ទាំងអស់) ដោយដាក់សំណើជាលាយលក្ខអក្សរជូនធនាគារ ។ រាល់ចំនួនដែលនឹងទូទាត់សងជាមុន ឬលុបចោលត្រូវធ្វើឡើងឱ្យបានគ្រប់ចំនួន បូករួមទាំងកំណើនការប្រាក់ ឬកម្រៃសេវាជាប្រាក់ដុល្លារអាមេរិកឱ្យបានទាន់ក្នុងថ្ងៃដែលត្រូវទូទាត់សងដូចបានបញ្ជាក់ ។ ធនាគាររក្សាសិទ្ធិក្នុងការយល់ព្រម ឬបដិសេធចំពោះការទូទាត់សងកម្ចីជាមុន ឬការលុបចោលកម្ចីទាំងនោះ ។

6.2 ការទូទាត់សងកម្ចីជាមុន និង/ឬការលុបចោលកម្ចីមុនកាលកំណត់ ត្រូវបង់កម្រៃ សេវាកម្មចំនួន 3% នៃប្រាក់កម្ចី ដែលត្រូវទូទាត់សងជាមុន ឬ 50 ដុល្លារអាមេរិកហើយត្រូវជ្រើសយកចំនួនណាដែលខ្ពស់ជាង ។ ធនាគាររក្សាសិទ្ធិក្នុងការកែប្រែគ្រប់ពេលលើកម្រៃសេវាកម្មដោយជូនដំណឹងជាមុនរយៈពេល 30 ថ្ងៃ ។

## 7. ការអនុញ្ញាត ការកាត់យកឥណទាន និងសំណងការខូចខាត

7.1 ធនាគារត្រូវបានអនុញ្ញាតឱ្យកាត់យកឥណទានក្នុងគណនី ឬគណនីណាមួយរបស់អ្នកខ្ចីជាមួយធនាគារ ដើម្បីទូទាត់សងប្រាក់ណាមួយដែលដល់កាលកំណត់ត្រូវសងឱ្យធនាគារ ដោយមិនចាំបាច់មានការជូនដំណឹង ។

7.2 អ្នកខ្ចីសន្យាទូទាត់សងសំណងការខូចខាតនានាដែលកើតមានចំពោះធនាគារដូចជាថ្លៃចំណាយលើការខាតបង់ និងការខូចខាតផ្សេងៗ (រួមទាំងកម្រៃសេវាកម្មមេធាវី និងសេវាកម្មផ្នែកច្បាប់ផ្សេងទៀត) ដែលធនាគារត្រូវបានទទួលដោយសារតែកំហុសរបស់អ្នកខ្ចីក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួនដូចមានចែងក្នុងកិច្ចព្រមព្រៀងនេះ ។

7.3 រាល់ប្រាក់សំណងដែលអ្នកខ្ចីធ្វើការទូទាត់សងទៅធនាគារត្រូវតែច្បាស់លាស់ និងដោយគ្មានពាក់ព័ន្ធនឹងការកាត់ទុក ការទាមទារ ពន្ធអាករ ពន្ធកាត់ទុក ឬជាប់ក្នុងទម្រង់លក្ខខណ្ឌណាមួយ លើកលែងតែច្បាប់តម្រូវឱ្យមានការកាត់ទុក ការទាមទារ ពន្ធអាករ ពន្ធកាត់ទុក ឬដាក់លក្ខខណ្ឌណាមួយដែលនៅក្នុងករណីនេះ ចំនួនសរុបដែលអ្នកខ្ចីត្រូវធ្វើការទូទាត់សង ត្រូវតែបូកបន្ថែមឱ្យបានគ្រប់ចំនួនជាចាំបាច់ ដើម្បីឱ្យធនាគារទទួលបានប្រាក់ដុលសរុបទាំងអស់នៃការកាត់ទុក ការទាមទារ ពន្ធអាករ ពន្ធកាត់ទុក ឬលក្ខខណ្ឌណាមួយស្មើនឹងប្រាក់ដែលត្រូវបានទទួលដោយគ្មានការកាត់ទុក ការទាមទារ ពន្ធអាករ ពន្ធកាត់ទុក ឬលក្ខខណ្ឌណាមួយដែលបានអនុវត្តរួច ។

## 8. ការប្រើប្រាស់កម្ចី

8.1 ក្នុងអំឡុងពេលកម្ចីនៅមានអត្ថិភាព អ្នកខ្ចីយល់ព្រមប្រើប្រាស់កម្ចីនោះ តាមគោលបំណងដែលបានបញ្ជាក់នៅក្នុងពាក្យស្នើសុំ និងបង្ហាញរាល់ព័ត៌មានដែលមានការពាក់ព័ន្ធដល់ការប្រែប្រួលក្នុងពេលប្រើប្រាស់កម្ចីនោះ ឬតាមការតម្រូវរបស់ធនាគារ ។

8.2 អ្នកខ្ចីទទួលប្រើប្រាស់កម្ចីក្នុងគោលបំណងដែលស្របតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ។ ធនាគារអាចស្នើឱ្យអ្នកខ្ចីផ្តល់ព័ត៌មានដែលពាក់ព័ន្ធក្នុងការប្រើប្រាស់កម្ចី ឬពិនិត្យអង្កេតលើគោលបំណងនៃកម្ចីនោះបានគ្រប់ពេលទាំងអស់ ។

## 9. មរណៈភាពរបស់អ្នកខ្ចី

9.1 អ្នកខ្ចីទទួលស្គាល់ និងយល់ព្រមថា ប្រសិនបើអ្នកខ្ចីទទួលមរណៈភាពមុនពេលកម្ចីត្រូវបានទូទាត់សងគ្រប់ចំនួន ឬអ្នកខ្ចីមិនអាចបន្តបំពេញការងាររបស់ខ្លួនបានដោយសារហេតុណាមួយ ឬឈប់រស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា កាតព្វកិច្ចក្នុងការទូទាត់សងរបស់អ្នកខ្ចី ត្រូវផ្លាក់ទៅលើទាយាទ ឬអ្នកទទួលដែលស្របច្បាប់ ឬបុគ្គលដែលច្បាប់អនុញ្ញាត ឬអាចត្រូវកាត់កងចេញពីទ្រព្យសកម្មរបស់អ្នកខ្ចី ទោះបីជាទ្រព្យនោះស្ថិតនៅកន្លែងណាឬក្រោមការគ្រប់គ្រងរបស់បុគ្គលណាមួយក៏ដោយ ។ អ្នកខ្ចីយល់ព្រមទទួលយកថា បុគ្គលទាំងនោះនឹងទទួលបានការជូនដំណឹងដ៏ត្រឹមត្រូវ និងយល់ព្រមតាមការរៀបចំនេះ ភ្លាមៗបន្ទាប់ពីធនាគារបានយល់ព្រមផ្តល់កម្ចីនេះ ។ ធនាគារមិនទទួលខុសត្រូវចំពោះសកម្មភាពណាមួយដែលពាក់ព័ន្ធដល់បុគ្គលទាំងនោះ ឬទ្រព្យសកម្មរបស់អ្នកខ្ចីក្នុងការទូទាត់សងកម្ចីឱ្យបានពេញលេញឡើយ ។

## 10. ការបង្ហាញព័ត៌មាន

ធនាគារអាចបង្ហាញព័ត៌មាននានាដែលពាក់ព័ន្ធទៅនឹងអ្នកខ្ចី គណនីរបស់អ្នកខ្ចី កិច្ចព្រមព្រៀងកម្ចី ឬការងារជំនួញនានាដែលស្ថិតនៅក្រោម ឬពាក់ព័ន្ធទៅនឹងកិច្ចព្រមព្រៀងកម្ចីនេះ ឬការងារជំនួញផ្សេងៗទៀតរបស់ធនាគារជាមួយអ្នកខ្ចី ដែលធនាគារយល់ឃើញថា សមស្របជូនទៅ៖ (ក) ទីស្នាក់ការកណ្តាល សាខាបុត្រសម្ព័ន្ធ សមាគម ឬស្ថាប័នពាក់ព័ន្ធ (ខ) បុគ្គលណាម្នាក់ (មានជាអាទិ៍ ផ្នែកត្រួតពិនិត្យ មន្ត្រីពង្រឹងច្បាប់ និយតករ តុលាការ ឬសាលាជម្រះក្តី) ដែលតម្រូវឱ្យបង្ហាញព័ត៌មានដោយ (i) អនុភាពនៃច្បាប់ ឬ (ii) បទបញ្ជា ការស្នើសុំ ឬការតម្រូវណាមួយ (ទោះបីជាច្បាប់នោះមាន ឬគ្មានអានុភាពនៃច្បាប់) លើដែនសមត្ថកិច្ចរបស់រាជរដ្ឋាភិបាល ឬអាជ្ញាធរផ្សេងទៀតនៃប្រទេសណាមួយ (គ) សវនករ ឬ អ្នកប្រឹក្សាជំនាញរបស់ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ និងក្រុមធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ដែលមានកាតព្វកិច្ចជាសម្ងាត់ក្នុងការរក្សាទុកពត៌មាននោះឱ្យធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ និងក្រុមធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ (ឃ) ភ្នាក់ងារណាមួយ ឬ តតិយជនដែលផ្តល់សេវាកម្មផ្សេងទៀតរបស់ធនាគារ

ជេ ត្រាស់ រ៉ូយ៉ាល់ និងក្រុមធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ ដែលមានកាតព្វកិច្ចជាសម្ងាត់ក្នុងការរក្សាទុកពតិមានសម្ងាត់នោះ (ង) តតិយជនជាអ្នកផ្ដល់សេវាកម្មណាមួយផ្នែកសន្តិសុខ ឬជំនួយឥណទាន (ប្រសិនបើមាន) (ច) បុគ្គលណាម្នាក់ដែលធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ បានទទួលនូវការធ្វើអនុប្បទានប្រគល់សិទ្ធិ ការចូលរួម ឬកិច្ចព្រមព្រៀងផ្សេងទៀតដែលមានទំនាក់ទំនងជាមួយកិច្ចព្រមព្រៀងកម្ចីនេះ និង (ឆ) ប្រសិនបើមានការរំលោភកាតព្វកិច្ចកើតឡើង ដូចបានកំណត់ក្នុងកិច្ចព្រមព្រៀងកម្ចីឥណទានរបស់អ្នកខ្ចី ឬតតិយជនណាមួយដែលធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ បានពិភាក្សាជាមួយលើការរៀបចំឡើងវិញ ឬការចាប់បង្ខំអ្នកខ្ចីឱ្យទូទាត់សងប្រាក់ដែលនៅជំពាក់ជាក់ស្ដែងជូនដល់ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់វិញ។

## 11. ការជូនដំណឹង និងទំនាក់ទំនងដោយធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់

11.1 អ្នកខ្ចីយល់ព្រមលើមធ្យោបាយទំនាក់ទំនងតាមរយៈលិខិតតាមប្រៃសណីយ៍ សារជាអក្សរ ទូរសារ សារទូរលេខ សារតាមប្រព័ន្ធអេឡិចត្រូនិច ឬតាមមធ្យោបាយអេឡិចត្រូនិចផ្សេងៗទៀត ដែលប្រើដោយធនាគារ។ ការជូនដំណឹង ឬការទាក់ទងដែលធនាគារត្រូវធ្វើឡើងចំពោះអ្នកខ្ចី ទោះតាមរយៈលិខិតប្រៃសណីយ៍ សារជាអក្សរ សារទូរលេខ សារតាមប្រព័ន្ធអេឡិចត្រូនិច ឬតាមរយៈមធ្យោបាយអេឡិចត្រូនិចផ្សេងៗទៀត ដោយប្រើនូវព័ត៌មានលម្អិតដែលអ្នកខ្ចី ផ្ដល់ឱ្យ ត្រូវបានចាត់ទុកថាបានទទួលដោយអ្នកខ្ចី។

11.2 អ្នកខ្ចី យល់ព្រមថារាល់ការណែនាំ ការជូនដំណឹង ការព្រមព្រៀង ឬទំនាក់ទំនងនានា ដែលអ្នកខ្ចីផ្ដល់ឱ្យទៅធនាគារ ត្រូវចងភ្ជាប់កាតព្វកិច្ចចំពោះអ្នកខ្ចី។ អ្នកខ្ចីយល់ព្រមផងដែរថា តាមរយៈទូរស័ព្ទ ឬទទួលទូរស័ព្ទ ដែលហៅចេញពីធនាគារ ឬពីតតិយជនដែលជាតំណាងស្របច្បាប់របស់ធនាគារ អាចធ្វើការថតសម្លេងរបស់អ្នកខ្ចីក្នុងពេលពិភាក្សាតាមរយៈទូរស័ព្ទ ដោយឆន្ទានុសិទ្ធិ។ អ្នកខ្ចីយល់ព្រមទៀតថាចំពោះខ្សែអាត់ ឬសម្លេងថតនៃទំនាក់ទំនងនេះអាចត្រូវបានធនាគារ ឬតតិយជនណាមួយយកទៅប្រើប្រាស់គ្រប់គោលបំណង រួមទាំងអាចយកខ្សែអាត់ថតសម្លេងនោះមកធ្វើជាភស្តុតាងនៅក្នុងបណ្ដឹងនានា ដូចជាបបណ្ដឹងរដ្ឋបាល ឬបណ្ដឹងយុត្តាធិការ។ អ្នកខ្ចីយល់ព្រមថា ធនាគារអាចយកកម្រៃ និងការចំណាយ ផ្សេងៗដែលទាក់ទងទៅនឹងដំណើរការ ដែលអ្នកខ្ចីណែនាំតាមរយៈទូរសព្ទ។

## 12. ការទទួលការណែនាំ និងទំនាក់ទំនងដោយអ្នកខ្ចី

12.1 អ្នកខ្ចីអនុញ្ញាតឱ្យធនាគារធ្វើសកម្មភាពនានា ដែលធនាគារយល់ឃើញថាសមស្រប តាមការណែនាំរបស់អ្នកខ្ចីទៅធនាគារ។ អ្នកខ្ចីអាចជូនដំណឹង ឬទាក់ទងទៅធនាគារម្ដងម្កាលអំពីការណែនាំរបស់ខ្លួន តាមរយៈលិខិតប្រៃសណីយ៍ អ៊ីម៉ែល ទូរស័ព្ទ ទូរលេខ ឬទូរសារ។ ធនាគារអាច (មិនមែនជាកាតព្វកិច្ច) តម្រូវឱ្យរៀបចំការណែនាំនោះ ឬធ្វើតាមទម្រង់ណាមួយជាក់លាក់ ឬតម្រូវឱ្យការណែនាំនោះ មានការបញ្ជាក់ច្បាស់លាស់ជាលាយលក្ខអក្សរ ឬករណីណាមួយឱ្យបានមុនពេលធនាគារ អនុវត្តតាមការណែនាំនោះ។

12.2 ទោះជាយ៉ាងណាក៏ដោយ ធនាគាររក្សាសិទ្ធិក្នុងការបដិសេធ ឬការយល់ព្រមលើការណែនាំនោះ ដោយធនាគារមិនចាំបាច់ផ្ដល់ហេតុផលឡើយ។ ប្រសិនបើធនាគារបានទទួលការណែនាំនោះ តាមរយៈលិខិតប្រៃសណីយ៍ អ៊ីម៉ែល ទូរស័ព្ទ ទូរលេខ ឬទូរសារ ធនាគារអាចអនុវត្តដោយផ្អែកលើការណែនាំទាំងនោះ ប្រសិនបើបុគ្គលិករបស់ខ្លួនបានទទួលការណែនាំនោះ ដោយជឿជាក់ថាបានទទួលពីអ្នកខ្ចី ឬ ក្នុងនាមអ្នកខ្ចី ហើយចាត់ទុកថាការណែនាំនោះត្រូវបានអនុញ្ញាតដោយស្របច្បាប់ត្រឹមត្រូវ និងពេញលេញ ទោះបីជាការណែនាំ នោះមិនត្រូវបានអនុញ្ញាតដោយស្របច្បាប់ត្រឹមត្រូវ និងពេញលេញ ហើយទោះបីជាការបញ្ជាក់តាមក្រោយពីអ្នកខ្ចីមានលក្ខណៈខុសគ្នាណាមួយពីការណែនាំនោះក៏ដោយ។

12.3 តាមរយៈនេះ អ្នកខ្ចីយល់ព្រម និងទទួលសងនូវសំណងការខូចខាតជូនធនាគារ និងធានាឱ្យធនាគារគេចផុតពីការទទួលខុសត្រូវក្នុងការខាតបង់ ការតវ៉ាបណ្ដឹង នីតិវិធីតុលាការ ការទាមទារ ព្យសនកម្ម តម្លៃ និងការចំណាយផ្សេងៗ (រួមបញ្ចូលទាំងកម្រៃសេវាកម្ម ផ្នែកច្បាប់ និងការចំណាយនានា) ដែលកើតមាន ឬនៅមានដោយផ្ទាល់ ឬដោយប្រយោលនៅធនាគារតាមគ្រប់រូបភាព និងគ្រប់មធ្យោបាយដែលកើតឡើងជាលទ្ធផលនៃ ឬដោយអនុលោមតាមបទបញ្ញត្តិ និងបទបញ្ជារបស់ធនាគារដោយយោងតាមលិខិតប្រៃសណីយ៍ អ៊ីម៉ែល ទូរស័ព្ទ ទូរលេខ ឬទូរសារដែលជាការណែនាំរបស់អ្នកខ្ចី។

## 13. ការប្រឆាំងនឹងការសំអាតប្រាក់ និងបញ្ញត្តិច្បាប់នានា

ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ អាចពន្យាពេលបង្អក ឬបដិសេធលើការបំពេញប្រតិបត្តិការណាមួយ ប្រសិនបើធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ សង្ស័យ ឬមានហេតុផលសមរម្យជាមូលដ្ឋានក្នុងការសង្ស័យថា (ក) ប្រតិបត្តិការនោះអាចបំពានលើច្បាប់ ឬបទបញ្ជាដែល

កំពុងអនុវត្ត (ខ) ប្រតិបត្តិការនោះមានការពាក់ព័ន្ធ ឬអាចពាក់ព័ន្ធទៅនឹងបុគ្គលណាម្នាក់ (រូបវ័ន្តបុគ្គល ក្រុមហ៊ុន ឬរដ្ឋាភិបាល) ដែលជាប់ទណ្ឌកម្ម ឬដែលពាក់ព័ន្ធដោយផ្ទាល់ ឬប្រយោលជាមួយបុគ្គលណាមួយដែលជាប់ទណ្ឌកម្មនៅក្រោមទណ្ឌកម្មសេដ្ឋកិច្ច និងពាណិជ្ជកម្មដែលអនុវត្ត ដោយសហរដ្ឋអាមេរិក អង្គការសហប្រជាជាតិ សហគមន៍អឺរ៉ុប អង្គការ ដែលរួមដោយប្រទេសមហាអំណាច ស្ថាប័នផ្លូវការ ឬប្រទេសណាមួយ (គ) ប្រតិបត្តិការអាចមានពាក់ព័ន្ធដោយផ្ទាល់ ឬប្រយោលជាមួយប្រាក់ចំណេញ ឬត្រូវបានអនុវត្តក្នុងគោលបំណងប្រព្រឹត្តនូវសកម្មភាពខុសច្បាប់ក្នុងព្រះរាជាណាចក្រកម្ពុជា ឬប្រទេសណាមួយ ហើយអ្នកខ្ចីទទួលស្គាល់ថា ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ មិនទទួលខុសត្រូវចំពោះបញ្ហាដែលកើតមានឡើងឡើយ ។

អ្នកខ្ចីត្រូវផ្តល់នូវរាល់ព័ត៌មានទាំងអស់ ដែលសមស្របទៅធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ តាមការទាមទាររបស់ធនាគារជេ ត្រាស់ រ៉ូយ៉ាល់ ដើម្បី៖ (ក) គ្រប់គ្រងនូវបទល្មើសក្នុងការសំអាតប្រាក់ហិរញ្ញប្បទាន ភេរវកម្ម ឬ សេដ្ឋកិច្ច និងទប់ស្កាត់ហានិភ័យក្នុងការទទួលទណ្ឌកម្ម ពាណិជ្ជកម្មឬ (ខ) គោរពតាមច្បាប់ ឬបទបញ្ញានានាឬ (គ) គោរពតាមគោលការណ៍ណែនាំ សំណើ ឬការទាមទារ (ទោះបីជាមាន ឬគ្មានអានុភាពផ្លូវច្បាប់) របស់រដ្ឋាភិបាលមានសមត្ថកិច្ច ឬអំណាចផ្សេងៗណាមួយ ។
អ្នកខ្ចីអះអាងជាមួយធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ លើការបំពេញប្រតិបត្តិការណាមួយដោយធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ តាមការណែនាំរបស់អ្នកខ្ចី នឹងមិនបំពានលើច្បាប់ ឬបទបញ្ញាណាមួយដែលមាននៅក្នុងប្រទេសណាមួយឡើយ ។

## 14. ច្បាប់គ្រប់គ្រង ការដោះស្រាយវិវាទ និងការកែប្រែលើបញ្ញត្តិ និងលក្ខខណ្ឌ

14.1 លក្ខខណ្ឌដែលមានក្នុងកិច្ចព្រមព្រៀងនេះ និងទម្រង់បែបបទ ត្រូវស្ថិតនៅក្រោមការគ្រប់គ្រង និងមានអត្ថន័យស្របនឹងច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ហើយរាល់ជម្លោះដែលកើតមានឡើង ឬមានទំនាក់ទំនងនឹងលក្ខខណ្ឌ និងកិច្ចព្រមព្រៀងកម្ចីនេះប្រសិនបើចាំបាច់ ធនាគារអាចដាក់ពាក្យបណ្តឹងទៅតុលាការតាមច្បាប់ ឬសាលាជម្រះក្តីនៃ យុត្តាធិការណាមួយដែលធនាគារយល់ឃើញថាសមស្រប ហើយក្នុងករណីនេះ ច្បាប់ដែលអនុវត្តចំពោះតុលាការ ត្រូវមានឧត្តមានុភាព ហើយអ្នកខ្ចីត្រូវគោរពតាមសេចក្តីសម្រេចរបស់តុលាការ ។

14.2 អ្នកខ្ចីយល់ព្រមថា ធនាគារមានឆន្ទានុសិទ្ធិ ក្នុងការកែប្រែ ការបន្ថែម ការកែប្រែឡើងវិញ ឬការផ្លាស់ប្តូរនូវវិធានណាមួយនៅក្នុងបញ្ញត្តិ និងលក្ខខណ្ឌ និងអត្រាការប្រាក់ កម្រៃសេវា និងសោហ៊ុយផ្សេងៗ ដែលទាក់ទងទៅនឹងកម្ចី ដោយផ្តល់ដំណឹងឱ្យអ្នកខ្ចីតាមការព្រមព្រៀង ទៅលើមធ្យោបាយទំនាក់ទំនងដែលមានចែងនៅខាងលើ ហើយការកែប្រែទាំងនេះ ត្រូវមានអានុភាពភាពក្នុងរយៈពេល 30 ថ្ងៃបន្ទាប់ពីជូនដំណឹងពីការផ្លាស់ប្តូរ ហើយការផ្លាស់ប្តូរនេះត្រូវចងភ្ជាប់ជាកាតព្វកិច្ចដល់អ្នកខ្ចីដោយពុំចាំបាច់មានការព្រមព្រៀងពីអ្នកខ្ចីឡើយ ។ បន្ថែមលើមធ្យោបាយទំនាក់ទំនងដូចដែលមានចែងនៅក្នុងប្រការ 12 និងប្រការ 13 នៃបញ្ញត្តិនិងលក្ខខណ្ឌនេះ ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ អាចជូនដំណឹងទៅអ្នកខ្ចីតាមរយៈគេហទំព័រ សាខារបស់ខ្លួន ការផ្សាយពាណិជ្ជកម្ម និងការជូនដំណឹងតាមរយៈ សារព័ត៌មានជាតិប្រចាំថ្ងៃ។ ការជូនដំណឹងនេះត្រូវបានចាត់ទុកថាអ្នកខ្ចី បានទទួលតាមរយៈការផ្សព្វផ្សាយតាមមធ្យោបាយទាំងនោះ ។

## 15. បញ្ញត្តិទូទៅ

15.1 ប្រសិនបើបញ្ញត្តិនិងលក្ខខណ្ឌទាំងនេះ ឬផ្នែកណាមួយនៃប្រការខាង លើត្រូវបានចាត់ទុកជាមោឃៈ ឬមិនអាចអនុវត្តបាន ដោយអាជ្ញាធរមានសមត្ថកិច្ច ផ្នែកផ្សេងទៀត នៅតែមានសុពលភាពអនុវត្តដដែល ។

15.2 គ្មានការយឺតយ៉ាវ ឬការខកខានណាមួយរបស់ធនាគារក្នុងការអនុវត្ត ឬបង្ខំឱ្យអនុវត្ត (ទាំងស្រុង ឬដោយផ្នែក) នូវសិទ្ធិ ឬការទាមទារសំណងការខូចខាតនៃកិច្ចសន្យាកម្ចីនេះនឹងមិនធ្វើឱ្យប៉ះពាល់ដល់សិទ្ធិ ឬការទារសំណងការខូចខាតដែលធនាគារមាន ហើយនឹងមិនបង្កើតជាការលះបង់នូវសិទ្ធិណាមួយឡើយ ។

15.3 គ្មានការលើកលែងរបស់ធនាគារចំពោះការបំពាន ឬមិនគោរពលើបញ្ញត្តិ និងលក្ខខណ្ឌណាមួយ ដែលអាចបង្កើតឱ្យមានការលើកលែងជាបន្តបន្ទាប់ចំពោះការបំពាន ឬការមិនគោរពដដែល ឬបញ្ញត្តិ និងលក្ខខណ្ឌដ៏ទៃទៀតនោះឡើយ ។ ការខកខានមិនបានទទួលឱកាស ឬអនុវត្តសិទ្ធណាមួយដែលធនាគារបានផ្តល់ឱ្យនេះ មិនអាចចាត់ទុកជាការលើកលែងចំពោះសិទ្ធិនោះឡើយ និងមិនអាចយកជាលេស ឬជាការលើកលែងអ្នកខ្ចីក្នុងការអនុវត្តតាម ឬបំពេញកាតព្វកិច្ចរបស់ខ្លួនដូចមានចែងនៅក្នុងបទបញ្ញត្តិ និងលក្ខខណ្ឌទាំងនេះឡើយ ។

15.4 ទោះបីជាមានការបកប្រែឯកសារនេះក៏ដោយ ប្រសិនបើមានភាពមិនស៊ីសង្វាក់គ្នា ភាសាអង់គ្លេសត្រូវមានឧត្តមានុភាព ។

# សាខាធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់

## រាជធានីភ្នំពេញ

សាខាក្រមួនស
(ការិយាល័យកណ្តាល)
ផ្ទះលេខ 20 វិថីក្រមួនស
កែងផ្លូវលេខ 67

សាខាវិមានឯករាជ្យ
ផ្ទះលេខ 100
មហាវិថីសម្តេចព្រះសីហនុ

សាខាផ្សារអូឡាំពិក
ផ្ទះលេខ 259-361-363
មហាវិថីសម្តេចព្រះសីហនុ

សាខាមាត់ទន្លេ
ផ្ទះលេខ 265 តីរវិថីព្រះស៊ីសុវត្ថិ

សាខាផ្សារដើមថ្កូវ
ផ្ទះលេខ 616A-B ផ្លូវលេខ 271

សាខាពេទ្យលោកសង្ឃ
ផ្ទះលេខ 1A-1B ផ្លូវលេខ 271

សាខាទឹកថ្លា
ផ្ទះលេខ 1E0-1E1 ផ្លូវលេខ 110A

សាខាស្ទឹងមានជ័យ
ផ្ទះលេខ 23-25A ផ្លូវលេខ 217

សាខាចោមចៅ
ផ្ទះលេខ 1B-2B និង 3B
ផ្លូវជាតិលេខ 4

សាខាទួលគោក
ផ្ទះលេខ 95C មហាវិថីលេខ 289

## សាខាខេត្ត

សាខាខេត្តសៀមរាប ផ្សារកណ្តាល
ផ្ទះលេខ 566-568 និង 570 ផ្លូវទេពវង្ស

សាខាខេត្តសៀមរាប ផ្សារលើ
ផ្ទះលេខ 556 ផ្សារលើ ផ្លូវជាតិលេខ 6

សាខាខេត្តព្រះសីហនុ
ផ្ទះលេខ 215 វិថីឯករាជ្យ

សាខាខេត្តបាត់ដំបង
ផ្ទះលេខ 2-4 និង 6 ផ្លូវលេខ 1

សាខាខេត្តកំពង់ចាម
វិថីព្រះមុនីវង្ស កែងវិថីនារីរ័ត្នកុសុមៈ

ឬតាមរយៈទូរស័ព្ទលេខ
ក្នុងស្រុក 023 999 000
អន្តរជាតិ +855 23 999 000
Email: ccc@jtrustroyal.com
SWIFT: TCABKHPP